មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
CAMBODIAN CENTER FOR HUMAN RIGHTS

សេចក្តីប្រកាសព័ត៌មាន
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០
សម្រាប់ការផ្សព្វផ្សាយជាបន្ទាន់

---

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចេញផ្សាយរបាយការណ៍ពិនិត្យមើលអំពីស្ថានភាពអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា

ភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០ -- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅថ្ងៃនេះចេញផ្សាយរបាយការណ៍ដែលមានចំណងជើងថា *ចេញជាចំហនៅព្រះរាជាណាចក្រកម្ពុជា ៖ ពលរដ្ឋខ្មែរដែលស្រលាញ់ភេទដូចគ្នា* ។ របាយការណ៍នេះគឺជាការបោះពុម្ពផ្សាយលើកដំបូង ដែលត្រូវបានរៀបចំឡើងដោយគម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងមានការគាំទ្រឧបត្ថម្ភពីសមាគមអប់រំផ្លូវភេទប្រទេសស៊ុយអែត។

មកដល់បច្ចុប្បន្នេះ គេឃើញមានការសិក្សាស្រាវជ្រាវតិចតួចបំផុតទៅលើស្ថានភាពអ្នកស្រលាញ់ភេទនៅកម្ពុជា។ ភាគច្រើននៃការសិក្សាទាំងនោះផ្តោតលើបញ្ហាសុខភាពដែលទាក់ទងនឹងអាកប្បកិរិយាផ្លូវភេទ។ របាយការណ៍នេះពិនិត្យមើលអំពីស្ថានភាពបច្ចុប្បន្ននៃអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា ស្តែងពីទស្សនៈវិស័យខាងសិទ្ធិមនុស្សដែលបានកត់សម្គាល់ថាអ្នកស្រលាញ់ភេទដូចគ្នាមានសិទ្ធិដូចមនុស្សទាំងអស់គ្នានៅក្នុងសហគមន៍ដែរ។ ការស្រាវជ្រាវនៅក្នុងរបាយការណ៍ធ្វើឡើងតាមរយៈកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលជាអ្នកស្រលាញ់ភេទដូចគ្នាប្រមាណជា៦០នាក់ ចាប់ពីខែកញ្ញា ដល់ខែតុលា ឆ្នាំ២០១០។ កិច្ចសម្ភាសន៍ធ្វើឡើងនៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ធំ សៀមរាប បាត់ដំបង បន្ទាយមានជ័យ ពោធិសាត់ កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ និង ព្រះសីហនុ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានជួបជាមួយអ្នកផ្តល់បទសម្ភាសន៍ជាលក្ខណៈក្រុម និងលក្ខណៈបុគ្គល ដែលប្រើវិធីសម្ភាសន៍មិនមានលក្ខណៈរចនាសម្ព័ន្ធ។ របាយការណ៍នេះបានកត់សម្គាល់ឃើញថាអ្នក ស្រលាញ់ភេទដូចគ្នាមានការប្រឈមជាពិសេស គឺការមិនរាប់រកពីក្រុមគ្រួសារ និងសហគមន៍ដែលបានបណ្តាលឲ្យមានស្ថានភាពសេដ្ឋកិច្ចកាន់តែលំបាក និងការរើសអើងពីនិយោជក និងអាជ្ញាធរដូចជាប៉ូលីសជាដើម។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសង្ឃឹមថា របាយការណ៍នេះនឹងក្លាយជាមធ្យោបាយមួយមានប្រយោជន៍សម្រាប់លើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រឈមនាពេលបច្ចុប្បន្នទៅលើប្រពលរដ្ឋកម្ពុជា ដែលស្រលាញ់ភេទដូចគ្នា ព្រមទាំងជម្រុញឲ្យមានការទទួលស្គាល់អ្នកស្រលាញ់ភេទដូចគ្នានៅក្នុងក្រុមគ្រួសារ និងសហគមន៍នៅទូទាំងប្រទេស។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងបន្តធ្វើការជាមួយបុគ្គល និងក្រុមអ្នកស្រលាញ់ភេទដូចគ្នាដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការចងក្រងឯកសារ និងរាយការណ៍ការរើសអើង និងការរំលោភបំពាន ព្រមទាំងធ្វើការតស៊ូមតិឲ្យមានការទទួលស្គាល់សិទ្ធិជាមូលដ្ឋានរបស់ពួកគេ។ លោកអ្នកអាចស្វែងរករបាយការណ៍នេះបានជាភាសាខ្មែរ និងភាសាអង់គ្លេសនៅលើ គេហទំព័រសិទ្ធិមនុស្សកម្ពុជា www.sithi.org និងនៅលើគេហទំព័រមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា www.cchrcambodia.org។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក ស្រុន ស្រ៊ន អ្នកសម្របសម្រួលគម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា
ទូរស័ព្ទលេខ + ៨៥៥ ១២ ២០២ ៩៩៩
អ៊ីម៉ែល: srornsrun@cchrcambodia.org

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ទូរស័ព្ទលេខ៖ +៨៥៥១២ ៤០ ៤០ ៥១
អ៊ីម៉េល៖ ouvirak@cchrcambodia.org